ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

សាលក្រមព្រហ្មទណ្ឌលេខ:៤០៥ គ

ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦

សំណុំរឿងព្រហ្មទណ្ឌលេខ: ២៩៨

ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥

# ត ា ង ន ា ម ប្រ ជ ា រ ា ស្ត្រ ខ្មែរ

សាលាដំបូងខេត្តកំពត

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពត។

- បើកសវនាការ: នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ វេលាព្រឹក។
- ប្រកាសសាលក្រម: នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ វេលារសៀល។

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ២៩៨ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ដែលមានជនជាប់ចោទ:

ឈ្មោះ [redacted] ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត មានទីលំនៅនៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត។ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ។ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ត្រូវបានជាប់ចោទពីបទ: **ប៉ុនប៉ងឃាតកម្ម(ប្រើកាំបិត)** ប្រព្រឹត្តនៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត កាលពីថ្ងៃទី ១៦.០៤.២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ២៧ និង១៩៩ នៃក្រមព្រហ្មទណ្ឌ ។

Scanned by CamScanner

ដែលមាន[redacted]ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទខាងលើ។

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៣១១ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត។

**ជនរងគ្រោះ**

ឈ្មោះ [redacted] ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត។

**ដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted]ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត ។

**ឯអង្គហេតុនៃរឿងមានដូចតទៅៈ**

កាលពីថ្ងៃទី ១៦.០៤.២០១៥ វេលាម៉ោង ១០យប់ នៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត មានករណីប៉ុនប៉ងឃាតកម្ម (ដោយប្រើកាំបិត) បានកើតឡើង បង្កដោយជនសង្ស័យឈ្មោ[redacted] បានពួនស្ទាក់កាប់ទៅលើជនរងគ្រោះឈ្មោ[redacted]បណ្តាលឱ្យរងរបួសពីលើក្បាលចំហៀងខាងស្តាំហូរឈាមជាទម្ងន់ ខណៈដែលជនរងគ្រោះចេញពីកន្លែងពិធីឡើងផ្ទះ ដល់ចំណុចក្បែរគុម្ពឫស្សីចំងាយ ២០ ម៉ែត្រ ពីផ្ទះពិធីជាមួយប្រពន្ធ និងកូនតូច ០៣នាក់។

**នាពេលសវនាការ**

**ក្រោយពីបានៈ**

- ស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោ[redacted]
- ស្តាប់ចម្លើយជនរងគ្រោះ[redacted]
- ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]
- ស្តាប់អំណានចម្លើយសាក្សី[redacted]
- ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាង និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

Scanned by CamScanner

## សំអាងហេតុ

១-តាមរបាយការណ៍ស៊ើបអង្កេតសន្និដ្ឋាន ដោយមន្ត្រីនគរបាលយុត្តិធម៌ មានលក្ខណៈគ្រប់គ្រាន់អាចបញ្ជាក់បានថា ពិតជាមានអំពើប៉ុនប៉ងឃាតកម្ម កាលពីថ្ងៃទី ១៦.០៤.២០១៥ នៅត្រង់ចំណុចភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត បង្ករឡើងដោយឈ្មោ[redacted]បកកាំបិតកាប់ទៅលើជនរងគ្រោះឈ្មោ[redacted]ក្បាលឱ្យបែកក្បាលហូរឈាមជាទម្ងន់ ប្រាកដមែន។

២-ជនជាប់ចោទនៅដំណាក់កាលចៅក្រមស៊ើបសួរបានឆ្លើយថា កាលពីថ្ងៃទី ១៦.០៤.២០១៥ ខ្លួនបានទៅចូលរួមពិធីឡើងផ្ទះ [redacted]ប្រាកដមែន ខ្លួនទៅតាំងពីម៉ោង ៥ល្ងាច ហើយខ្លួនត្រលប់មកវិញនៅម៉ោង ៨ ទៅ ៨ និង ៣០នាទី ពេលត្រលប់មកវិញមានគ្នា ៣នាក់ ឈ្មោ[redacted]រូបខ្លួន។ ពេលមកដល់ផ្ទះហើយខ្លួនមិនបានទៅណាទេ ខ្លួនចូលដេករហូតដល់ភ្លឺ ក្រៅពីបងប្អូន ម្តាយរបស់ខ្លួន អ្នកក្រៅមិនមានអ្នកណាដឹងថាខ្លួនបានទៅដេកនោះទេ។ ខ្លួនមិនបានយកដប ឬ កាំបិត វាយ ឬកាប់ទៅលើឈ្មោះ [redacted]កន្លងមកខ្លួនមិនដែលមានទំនាស់ជាមួយឈ្មោ[redacted]ាះទេ។ នៅថ្ងៃនោះខ្លួនពាក់អាវខៀវក្រមៅ និងស្លៀកខោខៅបយជើងវែង នៅក្នុងអំឡុងឆ្នាំ ២០១២ រដូវភ្ជុំឈ្មោះ [redacted]បានវាយខ្លួនបែកភ្នែកខាងស្តាំ នៅថ្ងៃទី ១៦.០៤.២០១៥នោះ ខ្លួនមិនមានបញ្ហាអ្វីជាមួយឈ្មោះ [redacted]ទេ។ នៅម៉ោង ៨ និង ៣០នាទី ឈ្មោ[redacted]កម្មវិធីនោះ បានឃើញខ្លួនចេញពីកម្មវិធីនោះដែរ។ អ្នកទាំងបីនាក់នោះដឹងថាខ្លួនទៅផ្ទះ ហើយអ្នកទាំងបីនោះនៅកម្មវិធីនោះរហូត ខ្លួនមកដល់ផ្ទះប្រហែលម៉ោង ៨កន្លះជាង ដឹងថាអ្នកទាំងបីនោះដឹងថាខ្លួនដេកទល់ភ្លឺដោយរបៀបណាទេ។

-តាមចម្លើយរបស់ជនរងគ្រោះ បានអះអាងថា នៅថ្ងៃកើតហេតុនោះ ថ្ងៃទី ១៦.០៤.២០១៥ វេលាម៉ោង ៩យប់ ខ្លួនបានចេញពីពិធីឡើងផ្ទះគេ ជាមួយប្រពន្ធ និង កូន ០៣នាក់។ ពេលដើរដល់ខាងត្បូងពិធីស្រាប់តែឈ្មោះ[redacted]ចេញពីគុម្ពឫស្សីមកកាប់ខ្លួនចំក្បាល ហើយវារត់ទៅត្បូងបាត់ទៅ។ ខ្លួនមិនធ្លាប់មានទំនាស់ជាមួយឈ្មោ[redacted]ឪពុករបស់ចំរើនធ្លាប់មានទំនាស់ជាមួយបងប្អូនជីដូនមួយខ្លួន។ កាលពីក្នុងអំឡុងអំឡុងឆ្នាំ២០១២ ពេលភ្ជុំនោះ គឺមានការឈ្លោះគ្នាជាមួយប្អូនជីដូនមួយខ្លួន និងឈ្មោ[redacted]ពេលនោះខ្លួនឈរមើល មិនបានចូលរួមវាយជាមួយគេទេ។ នៅពេលយប់កើតហេតុនោះខ្លួនឃើញមុខចំរើន ច្បាស់។ វាពួននៅគុម្ពឫស្សី ខ្លួនឮសូរសើរបជើងពីក្រោយទើបងាកទៅទើបមើលឃើញ។

-ដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយថា ឪ[redacted] ត្រូវជាជីតួតមួយម្តាយរបស់ខ្លួន។ ពេលយប់កើតហេតុនោះខ្លួនដើរជាមួយប្តី និងកូន ខ្លួនដើរពីមុខប្តី។ ពេលកាប់នោះគឺ [redacted]ពួននៅគុម្ពឫស្សី ចេញមកកាប់ប្តីរបស់ខ្លួន រួ[redacted]ត់ពីកើតផ្ទះកម្មវិធីទៅត្បូងទៅ។

-តាមចម្លើយរបស់សាក្សីឈ្មោះ[redacted]បានឆ្លើយប្រហាក់ប្រហែលគ្នាថា ពួកខ្លួនមិនបានឃើញហេតុការណ៍ផ្ទាល់ទេ គឺឈ្មោ[redacted]ជាអ្នកប្រាប់ខ្លួនថាឈ្មោះ [redacted]នវាយខ្លួននឹងដបបែកក្បាល ហើយពួកខ្លួនបានឃើ[redacted]បកក្បាលហូរឈាមពិតមែន។

Scanned by CamScanner

-សាក្សីឈេ[redacted]ងថា នៅយប់នោះ គឺពួក ខ្លួននៅមើលរឿងភាគថៃនៅផ្ទះរបស់ឈ្មោះ[redacted]ាមួយបងប្អូន[redacted] មនុស្សជាច្រើនទៀត តាំងពីម៉ោង៨ជាងយប់ រហូតដល់ម៉ោងដប់ទើបត្រឡប់ទៅផ្ទះរៀងៗខ្លួន ហើយមិនបានឃើញឈ្មោះ [redacted]ចេញទៅណាទេ គឺនៅផ្ទះរហូត។ ដោយឡែកសាក្សីឈ្មោ[redacted]បានអះអាងថា ក្រោយពីចេញពីផ្ទះកម្មវិធី[redacted]នត្រឡប់ទៅផ្ទះវិញនៅម៉ោង ៨ និង ៣០នាទី ពេលដល់ផ្ទះមិនបានចេញទៅណាទៀតទេ។

*តាមចម្លើយរបស់ជនរងគ្រោះ, ដើមបណ្តឹងរដ្ឋប្បវេណី និង ចម្លើយរបស់សាក្សីឈ្មោ[redacted]ឃើញថា ជនជាប់ចោទឈ្មោ[redacted]តជាបានប៉ុនប៉ងសំលាប់ ជនរងគ្រោះឈ្មោះ[redacted]កដមែន ដោយទង្វើរបស់ជនជាប់ចោទស្តែងចេញជាសកម្មភាព តែមិនបានសម្រេចដោយសកម្មភាពរបស់ខ្លួនមិនបានបង្កឱ្យជនរងគ្រោះស្លាប់ដូចបំណង គឺគ្រាន់តែបណ្តាលឱ្យជនរងគ្រោះបែកក្បាលហូរឈាមតែប៉ុណ្ណោះ។ ថ្វីត្បិតតែវាគ្រាន់តែបង្កឱ្យជនរងគ្រោះបែកក្បាល តែទង្វើរនេះវានឹងអាចបណ្តាលឱ្យជនរងគ្រោះបាត់បង់ជីវិត ប្រសិនបើការបង្កនេះប៉ះចំចំណុចសំខាន់នៅលើរាងកាយរបស់ជនរងគ្រោះ។*

៣-នាពេលសវនាការ លោកតំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំៈ ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី ឃើញថា[redacted]តជាបានកាប់ទៅលើជនរងគ្រោះ ដូចដែលចម្លើយរបស់បពន្ធជនរងគ្រោះ និងចម្លើយជនរងគ្រោះដែលថាធ្លាប់មានទំនាស់ជាមួយគ្នា។ ចម្លើយទាំងនេះមានបាតុសុីសង្វាក់ជាមួយនឹងលទ្ធផលស៊ើបអង្កេត និង កំណត់ហេតុរបស់ស្នងការនគរបាលខេត្តកំពត។ ហេតុដូច្នេះ តំណាងអយ្យការសុំតម្កល់បទចោទ ដូចមានក្នុងដីកាសន្និដ្ឋានស្ថាព ទុកជាបានការទាំងមូលដដែល។ អយ្យការប្តឹងសុំឱ្យតុលាការពិនិត្យ និងសម្រេច តាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានថាៈ ឆ្លងកាត់តាមការសួរដេញដោលនាពេលសវនាការ អំណានចម្លើយរបស់សាក្សី ឃើញថា ពុំមានភស្តុតាងណាមួយដើម្បីដាក់បន្ទុកលើកូនក្តីរបស់ខ្លួននោះទេ។ តាមរយៈមាត្រា ៣៨នៃក្រមព្រហ្មទណ្ឌ វិបតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ សុំឱ្យក្រុមប្រឹក្សាសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ។

៤- មានភាពគ្រប់គ្រាន់អាចឱ្យតុលាការជឿបានថាជនជាប់ចោទពិតជាបាន ប៉ុនប៉ងសម្លាប់ជនរងគ្រោះ នៅត្រង់ចំណុចភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត។ អំពើនេះ មានធាតុផ្សំជាបទប៉ុនប៉ងឃាតកម្ម ក្នុងមាត្រា ២៧ និង ១៩៩ នៃក្រមព្រហ្មទណ្ឌ។

៤.១-ជនជាប់ចោទជានីតិជន ហើយបានប្រព្រឹត្តសកម្មភាពខាងលើ ដោយចេតនាយល់ដឹងគ្រប់គ្រាន់

៤.២-មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ[redacted]បទ **ប៉ុនប៉ងឃាតកម្ម (ប្រើកាំបិត)** ប្រព្រឹត្តនៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត កាលពីថ្ងៃទី ១៦.០៤.២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ២៧ និង១៩៩ នៃក្រមព្រហ្មទណ្ឌ ។

Scanned by CamScanner

៤.៤-គប្បីប្រកាសទណ្ឌកម្មលើជនជាប់ចោទ[redacted]០ឆ្នាំ(ដប់ឆ្នាំ) ដោយពិចារណាដល់ភាពធន់ស្រាល នៃសកម្មភាពល្មើស ផលប៉ះពាល់ និងព្យសនកម្ម ដែលកើតចេញពីអំពើល្មើស និងស្ថានភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ដូចខាងក្រោម:

-អំពើល្មើសរបស់ជនជាប់ចោទ ថ្វីត្បិតតែមិនបានបង្កឱ្យជនរងគ្រោះបាត់បង់ជីវិត តែទង្វើនេះគឺកើតចេញពីចេញចេតនាចង់ផ្តាច់ជីវិតរបស់ជនរងគ្រោះ។ ម្យ៉ាងទៀត ជនជាប់ចោទ មិនបានចូលខ្លួនមកឆ្លើយដោះសារនាពេលសវនាការតាមការកោះហៅរបស់តុលាការនោះទេ។ ទង្វើទាំងនេះហើយ ដែលនាំឱ្យតុលាការផ្តន្ទាទោសជបជាប់ចោទ ដូចក្នុងចំណុច ៣.៤ ។

៥-ប្រពន្ធរបស់ជនរងគ្រោះឈ្មោ[redacted]បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្តចំនួន ៤.០០០.០០០៛ (បួនលានរៀល) ឃើញថា បណ្តឹងនេះធ្វើឡើងមានលក្ខណៈ ត្រឹមត្រូវតាមមាត្រា ១៣, ១៤, ១៥, ២១ និង ២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការព្រហ្មទណ្ឌ អាចពិនិត្យ និងសម្រេចបាន តាមមាត្រា ២៣ និង៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ តាមការពិនិត្យឃើញថា ការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនច្រើន ដែលគប្បីឱ្យតុលាការធ្វើការបន្ធូបន្ថយមួយផ្នែក។

## <u>សេចក្តីសម្រេច</u>

១-ផ្តន្ទាទោសឈ្មោ[redacted]ទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត មានទីលំនៅនៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត។ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោ[redacted]សពីមុនគ្មាន។ (ក្រៅឃុំ)

**ដាក់ពន្ធនាគារកំណត់ចំនួន ១០ឆ្នាំ (ដប់ឆ្នាំ)**។ ពីបទ **ប៉ុនប៉ងឃាតកម្ម**។

ប្រព្រឹត្តនៅភូមិត្រពាំងបឹង ឃុំត្រមែង ស្រុកឈូក ខេត្តកំពត កាលពីថ្ងៃទី ១៦.០៤.២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ២៧ និង ១៩៩ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted]ងសំណងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ឈឹង ស្រីពៅ** ចំនួន *២.០០០.០០០រៀល (ពីរលាន)*។ ការទាមទារលើសពីនេះ បដិសេធចោល។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតច[illegible]ច្បាប់ដើម

កំពត [illegible]

[redacted]

Scanned by CamScanner